# រាជបណ្ឌិត្យសភាកម្ពុជា

## លទ្ធផលកិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ
## នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៅខែធ្នូ ឆ្នាំ២០១៨

( ចងក្រងដោយ៖ RAC Media; ប្រភពឯកសារ៖ កជភខ )

## ១-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨

ថ្ងៃអង្គារ ១២រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ជួរ គារី បានបន្តប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការអក្សរសិល្ប៍ បានចំនួន ០៧ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- ប្រលោមលោកស្នេហា<br>អ. love novel<br>បារ. roman d'amour | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធលើកយកបញ្ហាស្នេហា រវាងបុរសនារីមកចោទនិងដោះស្រាយ។<br>ឧទាហរណ៍ រឿងបីសាចស្នេហា រឿងទុំទាវ ...។ |
| ២- ប្រលោមលោកមនោសញ្ចេតនា<br>អ. sentimental novel<br>បារ. roman sentimental | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធលើកយកគំនិត ទស្សនៈទាក់ទង ទៅនឹងការរិះគិតទៅតាម អារម្មណ៍ ចិត្ត មកចោទនិងដោះស្រាយ ដើម្បីរំឭកដាស់តឿន ណែនាំឱ្យអ្នកអាន អ្នកស្ដាប់ លះបង់អកុសលធម៌ ប្រព្រឹត្តកុសលធម៌។<br>ឧទាហរណ៍ រឿងផ្កាស្រពោន រឿងកុលាបប៉ៃលិន ...។ |
| ៣- ប្រលោមលោកអាសអាភាស<br>អ. erotic novel<br>បារ. roman érotique | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធលើកយកបញ្ហាទាក់ទងនឹងភាពស្រើបស្រាលនៃកាមតណ្ហាមកលាតត្រដាង ដោយបង្កប់នូវគំនិត ទស្សនៈអ្វីមួយ។<br>ឧទាហរណ៍ រឿងស្នេហ៍កាមទេព រឿងស្នេហ៍បញ្ច្រាសទិស ...។ |
| ៤- ប្រលោមលោកផ្សងព្រេង<br>អ. adventure novel<br>បារ. roman d'aventure | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធលើកយកជីវភាពបែបពនេចរ ទាក់ទងនឹង ការរុករកអ្វីមួយ ការធ្វើជំនួញ... មកចោទនិងដោះស្រាយ។ |

| | |
|---|---|
| | ឧទាហរណ៍ រឿងរ៉ូប៊ិនសុនគ្រូស្សូ (Robinson crusoe)... បោះពុម្ពនៅឆ្នាំ ១៧១៩ របស់អ្នកនិពន្ធអង់គ្លេស Daniel Defoe (1659-1731)។ |
| ៥- ប្រលោមលោកប្រវត្តិសាស្ត្រ<br>អ. historical novel<br>បារ. roman historique | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធតាក់តែងឡើងដោយលើកយកព្រឹត្តិការណ៍ឬតួអង្គប្រវត្តិសាស្ត្រ ក្នុងសម័យកាលណាមួយ មកចោទនិងដោះស្រាយ។<br>ឧទាហរណ៍ រឿងភូមិតិរច្ឆាន រឿងព្រះបាទជ័យវរ្ម័នទី៧ រឿងបន្ទាយលង្វែក...។ |
| ៦- ប្រលោមលោកយុទ្ធគុន<br>អ. fighting novel<br>បារ. roman de cape et d'épée | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធលើកយកបញ្ហាវិវាទ ការដណ្ដើមផលប្រយោជន៍អ្វីមួយ មកចោទនិងដោះស្រាយ តាមរយៈតួអង្គដែលមានចរិតជាអ្នកក្លាហាន ក្នុងការប្រយុទ្ធ។<br>ឧទាហរណ៍ រឿងអ្នកប្រដាល់១៣ស្រុក រឿងមហារំអិល រឿងនារីផ្សងព្រេង...។ |
| ៧- ប្រលោមលោកវិទ្យាសាស្ត្រ<br>អ. scientific novel<br>បារ. roman scientifique | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធលើកយកការពិសោធ ការស្រាវជ្រាវ របកគំហើញវិទ្យាសាស្ត្រ បច្ចេកវិទ្យា... របស់អ្នកប្រាជ្ញ អ្នកវិទ្យាសាស្ត្រ មកចោទនិងដោះស្រាយ។ |

## ២-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៨

ថ្ងៃពុធ ១៣រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម បានបន្តប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការគីមីវិទ្យា និង រូបវិទ្យា បានចំនួន១០ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- អាស៊ីដកាបុកស៊ីលិក<br>អ. carboxylic acid<br>បារ. acide carboxylique (m.) | សមាសធាតុសរីរាង្គមួយ ដែលមានផ្ទុកក្រុមកាបុកស៊ីល ហើយមានរូបមន្តទូទៅ R-COOH (R ជាក្រុមអ៊ីដ្រូកាបួ)។<br>ឧទាហរណ៍<br>អាស៊ីដអេតាណូអ៊ិកឬអាស៊ីដអាសេទិក <br>អាស៊ីដប៊ុយតាណូអ៊ិក  |
| ២- អាស៊ីដអាមីនេ<br>អ. amino acid | សមាសធាតុសរីរាង្គដែលមានផ្ទុកយ៉ាងតិចក្រុមអាមីន($-NH_2$)មួយនិងក្រុមកាបុកស៊ីល(-COOH)មួយ។ រូបមន្តទូទៅគឺ |

| | |
|---|---|
| បារ. acide aminé ( m. ) | $R\text{-}CH(COOH)(NH_2)$ (R ជាក្រុមអ៊ីដ្រូកាបួ)។<br>ឧទាហរណ៍ អាឡានីន  |
| ៣- អាមីន<br>អ. amine<br>បារ. amine ( f. ) | សមាសធាតុសរីរាង្គ និងក្រុមនាទី ដែលមានផ្ទុកអាតូមអាសូតជាគោលជាមួយទ្វេតាអេឡិចត្រុងសេរី។ រូបមន្តទូទៅគឺៈ $R\text{-}NH_2$ (R ជាក្រុមអ៊ីដ្រូកាបួ)។<br><br>មេទីលឡាមីន ឌីមេទីលឡាមីន ទ្រីមេទីលឡាមីន អាហ្ស៊ីរីឌីន |
| ៤- គីមីសរីរាង្គ<br>អ. organic chemistry<br>បារ. chimie organique ( f. ) | ផ្នែកមួយនៃគីមីវិទ្យាដែលសិក្សាពីទម្រង់ លក្ខណៈ និងប្រតិកម្ម នៃសមាសធាតុសរីរាង្គ។ |
| ៥- សមាសធាតុសរីរាង្គ<br>អ. organic compound<br>បារ. composé organique ( m. ) | សមាសធាតុទាំងឡាយណាដែលមានផ្ទុកអាតូមកាបូន។ |
| ៦- អ៊ីដ្រូកាបួអាលីហ្វាទិក<br>អ. aliphatic hydrocarbon<br>បារ. hydrocarbure aliphatique | អ៊ីដ្រូកាបួខ្សែលាត ឬបើក។<br>ឧទាហរណ៍ៈ<br><br>ប៊ុយតាន |
| ៧- អ៊ីដ្រូកាបួឆ្អែត<br>អ. saturated hydrocarbon<br>បារ. hydrocarbure saturé ( m. ) | អ៊ីដ្រូកាបួដែលមានសម្ព័ន្ធតែមួយជាន់ ឬសម្ព័ន្ធទោល។<br>ឧទាហរណ៍ៈ មេតាន $CH_4$ |
| ៨- អ៊ីដ្រូកាបួមិនឆ្អែត<br>អ. unsaturated hydrocarbon<br>បារ. hydrocarbure non-saturé ( m. ) | អ៊ីដ្រូកាបួដែលមានសម្ព័ន្ធពីរជាន់ឬបីជាន់។<br>ឧទាហរណ៍ $CH_2{=}CH_2$ $C_2H_2$ ( $CH \equiv CH$ ) |

| | |
|---|---|
| ៩- លំនឹងគីមី<br>អ. chemical equilibrium<br>បារ. équilibre chimique ( m. ) | សភាពនៃប្រតិកម្មគីមីដែលក្នុងនោះ កំហាប់នៃបណ្ដាអង្គធាតុប្រតិករ និងអង្គធាតុកកើត ឋិតនៅថេរ។<br>ឧទាហរណ៍ $2\ H_2O \rightleftharpoons H_3O^+ + OH^-$ |
| ១០-លក្ខណៈគីមី<br>អ. chemical property<br>បារ. propriété chimique ( f. ) | លក្ខណៈនានានៃរូបធាតុមួយដែលនឹងកើតមានឡើងក្នុងពេលឬក្រោយពេលប្រតិកម្មគីមី។ |

## ៣-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨

ថ្ងៃអង្គារ ៤កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ជួរ គារី បានបន្តប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការអក្សរសិល្ប៍ បានចំនួន ០៩ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១-ប្រលោមលោកឧត្ដមគតិនិយម<br>អ. idealism novel<br>បារ. roman idéalisme | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធលើកយកឧត្តមគតិណាមួយមកឆ្លុះបញ្ចាំងតាមរយៈអំពើឬសកម្មភាពរបស់តួអង្គដែលនិយមធ្វើអំពើល្អ មានចិត្តគំនិតប្រកបដោយគុណធម៌ និងមានអធ្យាស្រ័យក្នុងការរិះរកសេចក្ដីសុខចម្រើន ក្នុងគោលបំណងធ្វើឱ្យជីវិតរស់នៅបានល្អប្រពៃ មកចោទនិងដោះស្រាយ។<br>ឧទាហរណ៍ រឿងក្រុងសុភមិត្រ រឿងមាលាដួងចិត្ត រឿងកុលាបប៉ៃលិន ...។ |
| ២-ប្រលោមលោកតថនិយម<br>អ. realism novel<br>បារ. roman réalisme | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធលើកយកតថភាព នៃជីវិតជាក់ស្ដែងនៅក្នុងសង្គមនាសម័យកាលណាមួយ មកចោទនិងដោះស្រាយ។<br>ឧទាហរណ៍ រឿងភូមិតិរច្ឆាន រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់...។ |
| ៣-ប្រលោមលោកមនោគមវិជ្ជា<br>អ. ideology novel<br>បារ. roman d' idéologie | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធតាក់តែងឡើងដោយលើកបញ្ហាសង្គមមកចោទនិងដោះស្រាយ ផ្អែកលើទស្សនាទាននៃលទ្ធិណាមួយជាមូលដ្ឋាន។<br>ឧទាហរណ៍ រឿងគូលីកំណែន រឿងគ្រូបង្រៀនស្រុកស្រែ រឿងពលីកម្មម៉ែៗយើង...។ |
| ៤-ប្រលោមលោកវិទ្យាសាស្ត្រប្រឌិត<br>អ. science fiction novel | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធតាក់តែងឡើង ដោយលើកយកភាពអស្ចារ្យក្នុងវិទ្យាសាស្ត្រនិងភាពអស្ចារ្យតាមការស្រមើស្រមៃ មកចោទនិងដោះស្រាយ។ |

| | |
|---|---|
| បារ. roman de science fiction | ឧទាហរណ៍ រឿងអវតារ(AVATAR) របស់អ្នកនិពន្ធ ជេម កាម៉េរុន (James Cameron)។ |
| ៥-ប្រលោមលោកស៊ើបអង្កេត<br>អ. detective novel<br>បារ. roman de detective | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធលើកយកបញ្ហាចារកិច្ចក្នុងប្រទេសនិងក្រៅប្រទេស មកចោទនិងដោះស្រាយ។<br>ឧទាហរណ៍ រឿងទេវរូបត្បូងខ្មៅ រឿងតាមរកហង្សមាស រឿងក្អែបខ្មៅ ...។ |
| ៦-ប្រលោមលោកសម្រាប់យុវជន<br>អ. youth novel<br>បារ. roman pour la jeunesse | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធតាក់តែងឡើង ក្នុងគោលបំណងបណ្ដុះស្មារតីយុវជនឱ្យមានភាពស្មោះត្រង់ ភក្ដីភាព វីរភាព ក្ដីអំណត់ព្យាយាម... ឱ្យវៀរចាកអំពើហិង្សា អបាយមុខគ្រប់បែបយ៉ាង មកចោទនិងដោះស្រាយ។<br>ឧទាហរណ៍ រឿងកុលាបប៉ៃលិន ...។ |
| ៧-ប្រលោមលោកសម្រាប់កុមារ<br>អ. children novel<br>បារ. roman pour les enfants | ប្រលោមលោកមួយប្រភេទ ដែលអ្នកនិពន្ធតាក់តែងឡើងក្នុងគោលបំណង អប់រំកុមារឱ្យមានសុជីវធម៌ សីលធម៌ គុណធម៌ ភាពក្លាហាន ភាពឈ្លាសវៃ សេចក្ដីព្យាយាម ឧស្សាហ៍ រៀនសូត្រ ... មកចោទនិងដោះស្រាយ។<br>ឧទាហរណ៍ បណ្ដារឿងនៅក្នុងសៀវភៅម៉ុមនិងម៉ាប់...។ |
| ៨- អក្សរសិល្ប៍ប្រជាប្រិយ<br>អ. folk litterature<br>បារ. littérature folklorique (f.) | ស្នាដៃអក្សរសិល្ប៍មួយប្រភេទកើតឡើងតាមពាក្យសម្ដី ដែលពុំស្គាល់ឈ្មោះអ្នកនិពន្ធនិងមិនដឹងកាលបរិច្ឆេទច្បាស់លាស់ ហើយត្រូវបានប្រជាជននិយម ចេះចាំ និយាយតគ្នាពីមាត់មួយទៅមាត់មួយ ពីតំបន់មួយទៅតំបន់មួយ ពីសម័យកាលមួយទៅសម័យកាលមួយ។<br>អក្សរសិល្ប៍ប្រជាប្រិយមាន *តំណាលកថាប្រជាប្រិយ* និង*ពាក្យចួនប្រជាប្រិយ*។ |
| ៩- តំណាលកថាប្រជាប្រិយ<br>អ. folk tale<br>បារ. récits folklorique (m.) | ស្នាដៃអក្សរសិល្ប៍ប្រជាប្រិយមួយប្រភេទ ដែលប្រជាជនតំណាលអំពីរឿងរ៉ាវទាក់ទងនឹងបាតុភូតធម្មជាតិ ជំនឿ ទំនៀមទម្លាប់ប្រពៃណី ជីវភាពរស់នៅ ទំនាស់វិបត្តិសង្គម ភាពអច្ឆរិយៈដែលមានលក្ខណៈប្លែកហួសពីការពិតក្នុងសង្គមជាក់ស្ដែង...។<br>តំណាលកថាប្រជាប្រិយមាន *ទេវកថា ព្រេងកថា* និង *និទានកថា*។ |

# ៤-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨

ថ្ងៃពុធ ៥កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម បានបន្តប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការគីមីវិទ្យា និង រូបវិទ្យា បានចំនួន០៥ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- សម្ព័ន្ធកូវ៉ាឡង់<br>អ. covalent bond<br>បារ. liaison de covalence ( f. ) | សម្ព័ន្ធគីមីមួយប្រភេទដែលកើតឡើងដោយអាតូមពីរដាក់អេឡិចត្រុងមួយម្នាក់រួមគ្នា។ អេឡិចត្រុងរួមគ្នានេះឈ្មោះថាទ្វេតាអេឡិចត្រុង។<br>ឧទាហរណ៍ សម្ព័ន្ធកូវ៉ាឡង់ក្នុងម៉ូលេគុលមេតាន ( $CH_4$ )<br><br> |
| ២- សម្ព័ន្ធអ៊ីយ៉ុង<br>អ. ionic bond<br>បារ. liaison ionique ( f. ) | សម្ព័ន្ធគីមីមួយប្រភេទដែលកើតឡើងដោយកម្លាំងទំនាញរវាងអ៊ីយ៉ុងពីរមានបន្ទុកអគ្គិសនីផ្ទុយគ្នា។<br><br>$Na^+ + Cl^- \rightarrow NaCl$ |
| ៣- វ៉ាឡង់<br>អ. valence<br>បារ. valence ( f. ) | ចំនួនវិជ្ជមានដែលបង្ហាញពីសមត្ថភាពចងសម្ព័ន្ធរបស់អាតូមមួយជាមួយអាតូមផ្សេងទៀត។<br>ឧទាហរណ៍ អ៊ីដ្រូហ្សែនមានវ៉ាឡង់I អុកស៊ីហ្សែនមានវ៉ាឡង់II ។ |
| ៤- តារាងខួប/តារាងខួបនៃធាតុ<br>អ. periodic table<br>បារ. tableau périodique ( m. ) | ការតម្រៀបធាតុគីមីតាមលំដាប់នៃលេខអាតូម គ្រោងអេឡិចត្រុង និងលក្ខណៈគីមី ដែលបង្ហាញលក្ខណៈជាខួប។ |
| ៥- ឧស្ម័នកម្រ<br>អ. noble gas<br>បារ. gaz rare ( m. ) | ធាតុគីមីទាំងឡាយដែលស្ថិតនៅក្នុងក្រុមសូន្យ(ក្រុម១៨)នៃតារាងខួប រួមមាន អេល្យូម ( He ) នេអុង ( Ne ) អាហ្គុង ( Ar ) គ្រីបតុង ( Kr ) សេណុង ( Xe )...។ |